**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតពាក្យសុំកែតម្រូវលើពាក្យបណ្តឹង

**ដើមចោទ**

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យ ៖ .................................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី៖ ...........................................

.

លេខទូរស័ព្ទ ៖ ...................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី..................

**ចុងចម្លើយ**

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់មនោរម្យ ខណ្ឌ ៧មករា រាជធានីភ្នំពេញ។

**សូមគោរពជូន**

**លោកចៅក្រម J នៃសាលាដំបូងខេត្តបាត់ដំបង**

**<u>កម្មវត្ថុ</u> ៖** ដាក់**លិខិតពាក្យសុំកែតម្រូវ**លើពាក្យបណ្តឹងរបស់ X ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០២០

**<u>យោង</u> ៖** - ចំណុច ខ កថាខណ្ឌទី ២ មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

- សំណុំរឿងរដ្ឋប្បវេណីលេខ................ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០២០

**ដោយសារតែនៅក្នុងពាក្យបណ្តឹងដែលបានដាក់នៅថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០២០ មានកំហុស ដូច្នេះ ខ្ញុំសុំកែតម្រូវដូចខាងក្រោម៖**

## ក. កែតម្រូវមួយផ្នែកនៅលើ "ខ្លឹមសារនៃសាលក្រម និង ការចាត់ចែងបន្ទាប់បន្សំដែលដើមចោទទាមទារឲ្យតុលាការចេញ"

**ក.១. កែតម្រូវលេខ (៧) ចំណុច ក នៃ "ខ្លឹមសារនៃសាលក្រម និង ការចាត់ចែងបន្ទាប់បន្សំដែលដើមចោទទាមទារឲ្យតុលាការចេញ" ដូចខាងក្រោម[1]៖**

"មុនពេលកែ"

ដីចំណុច ១ ដែលកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ (តទៅហៅថា "ដី L 1" ) ជាកម្មសិទ្ធិរបស់កូនប្រុសរវាងដើមចោទ និង ចុងចម្លើយដែលមានឈ្មោះ សុក សុជាតិ។

"ក្រោយពេលកែ"

ដីចំណុច ១ ដែលកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ (តទៅហៅថា "ដី L 1" ) ជាកម្មសិទ្ធិអវិភាគរវាងដើមចោទ និង ចុងចម្លើយក្នុងចំណែកម្នាក់ៗ ចំនួន ១ ភាគ ២ ។

បង្គាប់ឲ្យលក់ដេញថ្លៃលើ "ដី L 2" ហើយយកចំនួនទឹកប្រាក់ដែលបានដកសោហ៊ុយសម្រាប់នីតិវិធីពីថ្លៃលក់នោះមកបែងចែកឲ្យទៅដើមចោទ និង ចុងចម្លើយក្នុងម្នាក់ៗ ចំនួន ១ ភាគ ២។

**ក.២. កែតម្រូវលេខ (៧) ចំណុច ច. នៃ " ខ្លឹមសារនៃសាលក្រម និង ការចាត់ចែងបន្ទាប់បន្សំដែលដើមចោទទាមទារឲ្យតុលាការចេញ" ដូចខាងក្រោម[2] ៖**

---

[1] នៅក្នុងការបែងចែកទ្រព្យសម្បត្តិ មិនអាចប្រទានកម្មទ្រព្យសម្បត្តិទៅឲ្យតតិយជនក្រៅពីប្តីប្រពន្ធបានទេ។ ប្រធានដែលទទួលបាននូវទ្រព្យសម្បត្តិ គឺ "សហព័ទ្ធនីមួយៗ" ដែលមានចែងនៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី២ មាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី។ ការណ៍ដែលឲ្យតតិយជនក្រៅពីសហព័ទ្ធនីមួយៗទទួលបាន គឺក្រមរដ្ឋប្បវេណីមិនទទួលស្គាល់នោះទេ។

[2] កាតព្វកិច្ចដោយសាមគ្គីភាពរបស់ប្តីប្រពន្ធ មិនអាចធ្វើការបែងចែកតែរវាងប្តីប្រពន្ធទេ។ ប្រសិនបើចង់ផ្លាស់ប្តូរអ្នកទទួកបន្ទុក ឬ ភាគទទួលបន្ទុកនៃកាតព្វកិច្ច ត្រូវពិភាក្សាជាមួយម្ចាស់បំណុល (ក្នុងរឿងក្តីនេះ

"មុនពេលកែ"

កាតព្វកិច្ចចំណុច ៦ ដែលបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ ជាបន្ទុករបស់ចុងចម្លើយ។

"ក្រោយពេលកែ"

លុបចោលចំណុចនេះ។

**ក.៣. កែតម្រូវលេខ (៧) ចំណុច ឆ នៃ " ខ្លឹមសារនៃសាលក្រម និង ការចាត់ចែងបន្ទាប់បន្សំដែលដើមចោទទាមទារឲ្យតុលាការចេញ" ដូចខាងក្រោម[3] ៖**

"មុនពេលកែ"

កាតព្វកិច្ចចំណុច ៧ ដែលបានកត់ត្រានៅក្នុង "បញ្ជីទ្រព្យសម្បត្តិរួម" នៃឧបសម្ព័ន្ធ ជាបន្ទុករបស់ចុងចម្លើយ។

"ក្រោយពេលកែ"

លុបចោលចំណុចនេះ។

សូម **លោកចៅក្រម** សម្រេចតាមការអះអាងខាងលើ ដោយក្តីអនុគ្រោះ។

ខេត្តបាត់ដំបង, ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០២០

**អ្នកតំណាងដោយអាណត្តិ**

P

គឺធនាគារ)។ ចំពោះវិធីលម្អិត សូមយោងការពន្យល់បន្ថែមនៅក្នុងឯកសារស្តីពីឧបសម្ព័ន្ធស្តីពី "ការអះអាងនីមួយៗរបស់ ដើមចោទ និង ចុងចម្លើយ" ចំណុច ※ 3 ។

[3] យោង Footnote 2។